**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៨ សសរ

# សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល**
**និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍**
**របស់ក្រុមហ៊ុន UNION Development Co., Ltd ខេត្តកោះកុង**
**និងគម្រោងវិនិយោគអភិវឌ្ឍន៍នៅតាមតំបន់ការពារធម្មជាតិទូទាំងប្រទេស**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- យោងសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ១.**- បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd នៅខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិ តាមខេត្ត ក្រុងពាក់ពន្ធ័ផ្សេងទៀត ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធាន

២- ឯកឧត្តម **សុខ ចិន្តា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣- ឯកឧត្តម **ទៅ សុវណ្ណ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន

៤- ឯកឧត្តម **ឆាន់ សារ៉ាវ៉ាន** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៥- ឯកឧត្តម **ធីក គ្រឿនទុន្តា** រដ្ឋលេខាធិការក្រសួងបរិស្ថាន អនុប្រធានប្រចាំការ

៦- ឯកឧត្តម **សួរ ទិចនំរ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៧- ឯកឧត្តម **លឹម សុគុន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៨- ឯកឧត្តម **ម៉ុល លឹម** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

៩- ឯកឧត្តម **ហ៊ុំ ថូវ៉ាក់ស៊ី** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន សមាជិក

១០- ឯកឧត្តមឧត្តមសេនីយ៍ទោ **ឆ្នាក់ សិទ្ធិ** មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១១- តំណាងមេធាវីរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០១ រូប សមាជិក

១២- ឯកឧត្តមអភិបាល ខេត្ត ក្រុង ដែលពាក់ព័ន្ធ នឹងតំបន់ការពារធម្មជាតិ សមាជិក

១៣- លោកវរៈសេនីយ៍ឯក **ទ្រី ឧមប៉ូរ៉ានឿន** តំណាងអគ្គស្នងការនគរបាលជាតិ សមាជិក

១៤- លោក **ចួន ហ៊ុនសុធីយ៉ា** តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក

១៥- អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ជា លេខាធិការដ្ឋាន

**ប្រការ២.**- គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី ភារកិច្ច និងបេសកកម្មដូចតទៅ:

១- ធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

២- ចូលរួមពិភាក្សា ផ្តល់យោបល់ លើការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

៣- ចូលរួមពិភាក្សា ផ្តល់យោបល់ និងដោះស្រាយលើរាល់ទម្រង់ប័ណ្ណសម្គាល់កម្មសិទ្ធិ និងលិខិតពាក់ព័ន្ធនឹងការកាន់កាប់ប្រើប្រាស់ដីធ្លីក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

៤- លើកវិធានការទប់ស្កាត់ និងដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យ ដែលកើតមានឡើងក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co.. Ltd. និង គម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

៥- បូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការចុះពិនិត្យ សិក្សា សម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស ។

ប្រការ៣.- បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង ដែលតំណាងឱ្យក្រសួង ស្ថាប័ន ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខណ្ឌសមត្ថកិច្ច ភារកិច្ច ដែលបានចែងក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីបូកសរុបលទ្ធផលការងារដែលសម្រេចបានជូនរាជរដ្ឋាភិបាល ។

ប្រការ៤.- គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្នុងក្រសួងបរិស្ថាន ។

ប្រការ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការនគរបាលជាតិ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង ដូចមានចែងក្នុងប្រកាស១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល:*

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ "ដើម្បីជូនជ្រាប និងអនុវត្ត"
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ